DEC.20-11-2002

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤២...អនក្រ.បក

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារ សំរាប់រៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីសម្បទានសេដ្ឋកិច្ចដីធ្លី

## ***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-យោងតាមសេចក្ដីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : បង្កើតក្រុមការងារសំរាប់រៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីសម្បទានសេដ្ឋកិច្ចដីធ្លី ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-ឯកឧត្ដម **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| ២-ឯកឧត្ដម **ចាន់ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣-ឯកឧត្ដម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-ឯកឧត្ដម **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-ឯកឧត្ដម **ម៉ឹន ម៉ើយ** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-ឯកឧត្ដម **សួន សិរិទ្ធិ** | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

/u/

**ប្រការ២ :** ក្រុមការងារនេះ មានភារកិច្ច :

- សិក្សាស្រាវជ្រាវទៅលើច្បាប់ និងលិខិតបទដ្ឋានជាធរមាន និងឯកសារនៃបណ្តាប្រទេស ក្នុងតំបន់ និងពិភពលោក ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការប្រើប្រាស់សម្បទានសេដ្ឋកិច្ចដីធ្លី ព្រមទាំងទិដ្ឋភាពផ្សេងៗ និងផលប៉ះពាល់នានា សំរាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំ និងចងក្រងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីសម្បទានសេដ្ឋកិច្ចដីធ្លីនៅព្រះរាជាណាចក្រកម្ពុជា ។
- ប្រជុំពិភាក្សាត្រួតពិនិត្យទៅលើខ្លឹមសារ ពាក្យពេចន៍នៃសេចក្តីព្រាងអនុក្រឹត្យនេះ អោយស្រប តាមស្ថានភាពជាក់ស្តែងនៅកម្ពុជា ដើម្បីដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង រួចធ្វើការកែសំរួល និងដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ៣ :** សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ប្រធានក្រុមការងារ មានសិទ្ធិប្រើប្រាស់ត្រា និងចំណាយថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការងាររៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ ។

**ប្រការ៤ :** ក្រុមការងារនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ៥ :** ក្រុមការងារនេះ ត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលចប់ភារកិច្ច ។

**ប្រការ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងឯកឧត្តម ដូចមានចែងក្នុង ប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ- កាលប្បវត្តិ